# សិក្ខាសាលាជាតិ
# ស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១១
# នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជធានី ខេត្ត
## ថ្ងៃទី ០២_០៣ ខែ មិថុនា ឆ្នាំ ២០១១
## រាជធានីភ្នំពេញ សាលប្រជុំក្រសួងមហាផ្ទៃ

---

សុន្ទរកថាបើក

**ឯកឧត្តម សក់ សេដ្ឋា**

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

- **ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកនៃក្រសួងស្ថាប័ននៅថ្នាក់ជាតិ**
- **ឯកឧត្តម លោកជំទាវ លោកស្រី អស់លោកតំណាងឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ**
- **អង្គសិក្ខាសាលាទាំងមូលជាទីគោរព**

ថ្ងៃនេះខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមក្នុងពិធីបើកសិក្ខាសាលាស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជធានី ខេត្តដ៏មានសារៈសំខាន់នាថ្ងៃនេះ។

ជាទូទៅ សិក្ខាសាលាស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ តែងតែត្រូវបានរៀបចំឡើងនៅក្នុងអំឡុងពេលនៃចុងឆ្នាំចាស់សម្រាប់ឆ្នាំបន្ទាប់។ ដោយឡែក សិក្ខាសាលារៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០១១នេះ បែរជាត្រូវបានរៀបចំឡើងនាថ្ងៃនេះ គឺមានន័យថា យើងមានការយឺតយ៉ាវប្រមាណ៥-៦ខែសម្រាប់ការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំនេះ។ ជំនួសមុខឱ្យ គ.ជ.អ.ប ក្នុងនាមជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់មេត្តាផ្តល់នូវការអាធ្យាស្រ័យ និងយោគយល់ចំពោះការយឺតយ៉ាវនេះ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់បានជ្រាបស្រាប់ហើយថា ទោះបីរាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈខ្ពស់ក្នុងការធ្វើកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក៏ដោយ ប៉ុន្តែផ្អែកលើលក្ខណៈស្មុគស្មាញនៃកំណែទម្រង់នេះ ទាមទារឱ្យយើងត្រូវមានការគិតគូរយ៉ាងប្រុងប្រយ័ត្នជាទីបំផុត និងត្រូវការរយៈពេលយូរអង្វែង ព្រមទាំងតម្រូវឱ្យមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់តួអង្គពាក់ព័ន្ធសំខាន់ៗ និងប្រជាពលរដ្ឋទូទាំងប្រទេស។ លើសពីនេះទៅទៀត កំណែទម្រង់នេះក៏តម្រូវឱ្យមាននូវការចំណាយយ៉ាងខ្ពស់ ដែលរាជរដ្ឋាភិបាលយើងមិនទាន់មានលទ្ធភាពគ្រប់គ្រាន់សម្រាប់គាំទ្រកិច្ចដំណើរការកំណែទម្រង់នេះទាំងស្រុងដោយខ្លួនឯងបាននៅឡើយ។ ជាក់ស្តែង ក្នុងអំឡុងពេលមួយទសវត្សរ៍កន្លងមកនេះ យើងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការសម្របសម្រួល និង

កៀរគរជំនួយពីដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ដើម្បីគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ជាទូទៅ ក្នុងអំឡុងពេលកន្លងមក ការគាំទ្រពីដៃគូអភិវឌ្ឍន៍ទាំងនោះភាគច្រើនត្រូវបានធ្វើឡើងតាមរយៈគម្រោងដោយឡែក១ ដែលរៀបចំឡើងដោយដៃគូអភិវឌ្ឍន៍នីមួយ១ ឬក្រុមដៃគូអភិវឌ្ឍន៍ផ្សេង១គ្នាផ្អែកទៅតាមតម្រូវការ និងល័ក្ខខ័ណ្ឌផ្សេង១គ្នារបស់ដៃគូអភិវឌ្ឍន៍នីមួយ១ទាំងនោះ។ ការគាំទ្រតាមបែបផែនរបៀបនេះ ត្រូវបានទទួលស្គាល់ថា នៅមិនទាន់បានផ្តល់លទ្ធភាពពេញលេញសម្រាប់ការលើកម្ពស់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និងបង្កលក្ខណៈគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍន៍សមត្ថភាព និងការផ្ទេរចំណេះដឹងដល់ស្ថាប័ន និងមន្ត្រីរដ្ឋាភិបាល ព្រមទាំងត្រូវចំណាយថវិកាច្រើនសម្រាប់កិច្ចប្រតិបត្តិការ និងជាពិសេស វាក៏បង្ហាញឱ្យឃើញពីការពិបាកក្នុងការសម្របសម្រួល និងការរៀបចំដើម្បីធានាបាននូវចីរភាពនៃកិច្ចដំណើរការកំណែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់យើងផងដែរ។

ក្នុងន័យពង្រឹងភាពជាម្ចាស់ ជំរុញឱ្យមានការចូលរួមយ៉ាងពេញលេញរបស់រាជរដ្ឋាភិបាលទាំងមូល និងបង្កើននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃកិច្ចដំណើរការកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានម្ចាស់ការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការរៀបចំនូវក្របខ័ណ្ឌគតិយុត្តជាមូលដ្ឋានបន្ថែមទៀតសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ នៅក្នុងឆ្នាំ២០០៩ និង២០១០ យើងបានរៀបចំកម្មវិធីជាតិរយៈពេល១០ឆ្នាំ ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវ និងជាមូលដ្ឋានចាំបាច់សម្រាប់ការគាំទ្រដល់ការអនុវត្តកិច្ចដំណើរការកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ លើសពីនេះ នៅក្នុងឆ្នាំ២០១០ យើងបានចំណាយពេលប្រមាណជាង៨ខែ សម្រាប់ការរៀបចំផែនការអនុវត្តរយៈ៣ឆ្នាំដំបូងនៃកម្មវិធីជាតិ ដែលយើងហៅកាត់ថា ផអ៣ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការអនុវត្តកម្មវិធីជាតិក្នុងបណ្តាឆ្នាំដំបូង១ និងធ្វើជាមូលដ្ឋានក្នុងការកៀរគរការគាំទ្រនានា។ ដើម្បីធានាដល់ការគ្រប់គ្រង និងការអនុវត្តកិច្ចដំណើរកំណែទម្រង់នេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំបង្កើតឱ្យមានការចុះហត្ថលេខាវវាង គ.ជ.អ.ប ជាមួយនឹងដៃគូអភិវឌ្ឍន៍សំខាន់១មួយចំនួនលើអនុស្សរណៈស្តីពីវិធីសាស្ត្រផ្អែកតាមកម្មវិធី ក្នុងគោលបំណងពង្រឹងភាពជាម្ចាស់ និងការប្រើប្រាស់នូវប្រព័ន្ធនានារបស់រាជរដ្ឋាភិបាល ព្រមទាំងធ្វើសុខដុមនីយកម្ម និងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយគាំទ្ររបស់ដៃគូអភិវឌ្ឍន៍។

ទោះបីជាឯកសារ ផអ៣ ត្រូវបានអនុម័តជាគោលការណ៍ដោយ គ.ជ.អ.ប នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ក៏ដោយ ក៏ប៉ុន្តែដើម្បីធានាដល់ការកៀរគរការគាំទ្រពីដៃគូអភិវឌ្ឍន៍ ឯកសារផអ៣នេះ ត្រូវបានដាក់ឱ្យធ្វើការវាយតម្លៃរួមគ្នាដោយដៃគូអភិវឌ្ឍន៍ ដើម្បីធានាបានការគាំទ្រដ៏មានសារៈសំខាន់របស់ដៃគូអភិវឌ្ឍន៍នានា។ ការវាយតម្លៃរួមគ្នានេះ ត្រូវបានប្រព្រឹត្តទៅដោយរលូន និងបានបញ្ចប់នៅដើមខែមីនាឆ្នាំ២០១១ ព្រមទាំងទទួលបានលទ្ធផលជាវិជ្ជមាន រួមជាមួយនឹងអនុសាសន៍សំខាន់១មួយចំនួន ដែលផ្តោតលើការកែលំអបន្ថែមនូវយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ យុទ្ធសាស្ត្រនៃការផ្ទេរចំណេះដឹង ការរៀបចំបន្ថែមនូវក្របខ័ណ្ឌគណនេយ្យភាពសង្គម និងការកែតម្រូវថវិកាប៉ាន់ស្មានរបស់ផអ៣។

ផ្អែកលើលទ្ធផលនៃការវាយតម្លៃរួមគ្នាលើឯកសារផអ៣ រដ្ឋាភិបាលស៊ុយអែត បានធ្វើការសម្រេចចិត្តផ្តល់ការគាំទ្រដល់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនូវមូលនិធិចំនួនប្រមាណ២៨លានដុល្លារ តាមរយៈ

កិច្ចព្រមផ្តល់ហិរញ្ញប្បទាន ដែលទើបបានចុះហត្ថលេខារវាងឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប និងឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា ជាមួយលោកជំទាវ **Anne Hoglund** ឯកអគ្គរដ្ឋទូតស៊ុយអែតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា តំណាងឱ្យរដ្ឋាភិបាលស៊ុយអែត នារសៀលថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ ថ្មីៗនេះ។

ការយឺតយ៉ាវក្នុងការរៀបចំ**ផអ៣** បានបណ្តាលឱ្យមានការយឺតយ៉ាវនូវការរៀបចំផ្តល់ហិរញ្ញប្បទានគាំទ្រពីដៃគូអភិវឌ្ឍន៍សម្រាប់ការចាប់ផ្តើមអនុវត្ត**ផអ៣** ជាពិសេសការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១១ ក្នុងរយៈពេលប្រាំខែដើមឆ្នាំកន្លងមកនេះ។ ទោះបីជាមានការយឺតយ៉ាវយ៉ាងនេះក្តី ក៏យើងបានចាប់ផ្តើមអនុវត្តនូវសកម្មភាពជាអាទិភាព និងចាំបាច់នានា នៅក្នុង៥ខែដើមឆ្នាំ២០១១នេះ ដោយប្រើប្រាស់ថវិកាដែលនៅសេសសល់មួយចំនួនពីគម្រោង PSDD ដែលបានអនុញ្ញាតិឱ្យប្រើប្រាស់នៅក្នុងត្រីមាសទី១នៃឆ្នាំ២០១១ និងប្រើប្រាស់មូលនិធិគាំទ្ររបស់កម្មវិធីដានីដានៃប្រទេសដាណឺម៉ាកដល់កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០១១។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

គោលបំណងសំខាន់នៃសិក្ខាសាលាជាតិរបស់យើងក្នុងរយៈពេលពីរថ្ងៃនេះ គឺផ្តោតជាសំខាន់ទៅលើការណែនាំដល់រាជធានី ខេត្ត ក្នុងការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០១១ និងការពិភាក្សាលើបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលត្រូវដោះស្រាយ និងអនុវត្តឱ្យបានសម្រេចនៅក្នុងឆមាសទី២នៃឆ្នាំ២០១១នេះ។ ជាការពិតណាស់ ផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នេះ គឺជាផែនការសកម្មភាព និងថវិកាឆ្នាំទី១របស់ផអ៣ដែលត្រូវរៀបចំឡើងតាមរបៀបថ្មីមួយ ដែលបានកំណត់នៅក្នុងផអ៣។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមគូសបញ្ជាក់ជាថ្មីម្តងទៀតជូនអង្គសិក្ខាសាលាថា ផអ៣ នឹងផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការអភិវឌ្ឍសមត្ថភាព និងការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រុង ស្រុក ការបន្តនិរន្តរភាពនៃការគាំទ្រដល់ថ្នាក់ឃុំ សង្កាត់ ព្រមទាំងការពង្រឹងតួនាទីថ្នាក់រាជធានី ខេត្តក្នុងនាមតំណាងឱ្យថ្នាក់ជាតិក្នុងការសម្របសម្រួល ការគាំទ្រ និងការត្រួតពិនិត្យមើលពីលើ។ ក្នុងដំណាក់កាលដំបូងនេះ ការគ្រប់គ្រង និងអនុវត្តផអ៣ ត្រូវបានបែងចែកជា៦អនុកម្មវិធី ដែលមានការពាក់ព័ន្ធជាមួយនឹងក្រសួង ស្ថាប័នសំខាន់ៗចំនួន៦នៅថ្នាក់ជាតិ។ អាស្រ័យហេតុនេះ ផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នេះ នឹងត្រូវរៀបចំឡើងដោយមានការបែងចែកនូវការទទួលខុសត្រូវទៅតាមអនុកម្មវិធីនីមួយៗ ទៅលើសកម្មភាពនានាដែលពាក់ព័ន្ធជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមក្របខ័ណ្ឌនៃការសម្របសម្រួល និងគ្រប់គ្រងជារួមរបស់លេខាធិការដ្ឋាន គ.ជ.អ.ប។ ក្នុងពេលបន្តិចទៀតនេះ អង្គសិក្ខាសាលានឹងបានស្តាប់នូវការបង្ហាញរបស់តំណាងក្រសួងស្ថាប័នដែលទទួលខុសត្រូវតាមអនុកម្មវិធីនីមួយៗ អំពីសកម្មភាពសំខាន់ៗរបស់ខ្លួនដែលពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រៅពីការបង្ហាញអំពីផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០១១ របស់អនុកម្មវិធីនីមួយៗ តំណាងលេខាធិការដ្ឋាន គ.ជ.អ.ប នឹងបង្ហាញអំពីរបៀបរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១១របស់រាជធានី ខេត្ត ព្រមទាំង

ដាក់ជូនអង្គសិក្ខាសាលាសម្រាប់ធ្វើការពិភាក្សាផងដែរ អំពីនីតិវិធីជ្រើសរើសមន្ត្រីអនុវត្តផអពក្រោមក្របខ័ណ្ឌនៃប្រព័ន្ធចំណាយប្រតិបត្តិការអាទិភាព អំពីប្រព័ន្ធរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផអព អំពីលទ្ធផលនៃការអនុវត្តកម្មវិធីសាកល្បងស្តីពីការប្រើប្រាស់សេវាវិស្វកម្មឯកជនសម្រាប់គាំទ្របច្ចេកទេសដល់ការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ សង្កាត់ និងប្រធានបទសំខាន់ៗផ្សេងៗទៀត ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

ឆ្លៀតក្នុងឱកាសនេះផងដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ ដែលបានចូលរួមចំណែកយ៉ាងសស្រាក់សស្រាំគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជារៀងរហូតកន្លងមក ។ ខ្ញុំសូមកោតសរសើរដល់ឆន្ទៈដ៏មោះមុត និងការខិតខំប្រឹងប្រែងចាប់ដៃគ្នា ដើម្បីពុះពារជំនះគ្រប់ឧបស័គ្គក្នុងការអនុវត្តសកម្មភាពសំខាន់ៗក្នុងរយៈ៥ខែដើមឆ្នាំ២០១១នេះ រហូតធានាបាននូវការតភ្ជាប់ និងឆ្លងផុតយ៉ាងរលូននូវដំណាក់កាលអន្តរកាលសម្រាប់ការចាប់ផ្តើមអនុវត្តផអពរបស់យើងនាពេលនេះ ។

ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំសូមជម្រាបជូនអង្គសិក្ខាសាលា ជាពិសេសរាជធានី និងខេត្តទាំងអស់ថា មកដល់ថ្ងៃនេះថ្នាក់ជាតិបានផ្តល់អនុលោមភាពលើផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់រាជធានី ខេត្តទាំងអស់រួចហើយ ។ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់រាជធានី ខេត្ត នឹងក្លាយទៅជាផែនទីបង្ហាញផ្លូវស្របច្បាប់សម្រាប់ការអភិវឌ្ឍរាជធានី ខេត្ត ។ ខ្ញុំសូមចូលរួមអបអរសាទរយ៉ាងក្រៃលែងចំពោះជោគជ័យដ៏ធំធេងនេះ ។

លើសពីនេះ ខ្ញុំសូមជម្រាបជូនផងដែរថា ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានទទួលការអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភាក្នុងពេលថ្មីៗកន្លងទៅនេះ ។ ផ្អែកលើច្បាប់នេះក្រុមការងាររួមមួយនៃលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំពុងតែរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតមូលនិធិក្រុង ស្រុក និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងការបង្កើតនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ក្រុង ស្រុកផងដែរ ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សេចក្តីព្រាងអនុក្រឹត្យនេះនឹងត្រូវបានរៀបចំបញ្ចប់ និងទទួលបានការអនុម័តដោយរាជរដ្ឋាភិបាលក្នុងពេលឆាប់ៗខាងមុខនេះ ដើម្បីធានាឱ្យក្រុង ស្រុកមួយចំនួនអាចមានលទ្ធភាពប្រើប្រាស់នូវមូលនិធិរបស់ខ្លួន ដែលបានត្រៀមបម្រុងផ្តល់ឱ្យដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់គម្រោងអភិវឌ្ឍន៍មួយចំនួននៅក្នុងឆ្នាំ២០១១នេះ ។

ក្នុងខណៈនៃការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១១សម្រាប់រាជធានី ខេត្ត ខ្ញុំក៏សូមជម្រាបជូនក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួននៅថ្នាក់ជាតិ ដែលធ្លាប់ទទួលបានការគាំទ្រពី គ.ជ.អ.ប ថា លេខាធិការដ្ឋាន គ.ជ.អ.ប បាន និងកំពុងគិតគូរធ្វើការបែងចែកធនធានសម្រាប់បន្តការគាំទ្រនៅក្នុងឆ្នាំ២០១១នេះ ។ លេខាធិការដ្ឋាន នឹងរៀបចំកិច្ចប្រជុំមួយជាមួយក្រសួង ស្ថាប័នទាំងនេះ ក្នុងពេលឆាប់ៗ ដើម្បីពិភាក្សាលើការងារនេះ ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

ជារួម យើងបានធ្វើដំណើរឆ្លងផុតយ៉ាងជោគជ័យនូវដំណាក់កាលអន្តរកាលដ៏លំបាកស្មុគស្មាញនាចុងឆ្នាំ២០១០ និងដើមឆ្នាំ២០១១កន្លងមក ដែលក្នុងនោះ ការព្យាយាមតស៊ូ អត់ធ្មត់ ដើម្បីពុះពារ ជំនះបញ្ហាប្រឈមនានារបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី គឺជាការរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវជោគជ័យនេះ។ យ៉ាងណាមិញ ស្ថានភាពនេះ កំពុងបង្កឱ្យមានអំរែកដ៏ធ្ងន់ធ្ងរដល់យើងទាំងអស់គ្នា ក្នុងការសម្រេចឱ្យបាននូវកិច្ចការសំខាន់ៗរបស់ឆ្នាំ តែក្នុងរយៈពេល៦ខែចុងឆ្នាំប៉ុណ្ណោះ។ ជាមួយគ្នានេះដែរ យើងទាំងអស់គ្នាត្រូវយល់ថា លទ្ធផលនៃរយៈពេល៦ខែចុងឆ្នាំនេះ ជាល័ក្ខខ័ណ្ឌវាស់វែងនៃការទទួលបាននូវការគាំទ្រយ៉ាងទូលំទូលាយបន្ថែមទៀតពីដៃគូអភិវឌ្ឍន៍នានា និងជាការធានាបាននូវមូលដ្ឋានគ្រឹះនៃទំនុកចិត្តរបស់ថ្នាក់ជាតិក្នុងការយកចិត្តទុកដាក់បង្កើនការផ្តល់នូវការទទួលខុសត្រូវ មុខងារ និងធនធាននានាកាន់តែច្រើនឡើងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងក្របខ័ណ្ឌនៃបែបផែនសហប្រតិបត្តិការថ្មី ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួងស្ថាប័នសំខាន់ៗនៅថ្នាក់ជាតិ លេខាធិការដ្ឋាន អ.ជ.អ.ប សង្ឃឹមយ៉ាងមុតមាំថា វិធីសាស្ត្រជាយុទ្ធសាស្ត្រនានារបស់ ផអ៣ នឹងនាំឱ្យយើងឈានឆ្ពោះទៅរកការសម្រេចដោយជោគជ័យនូវផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងគោលដៅចម្បងៗនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ទីបញ្ចប់ខ្ញុំសូមប្រសិទ្ធិពរជ័យមហាបវរប្រសើរជូនដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ និងសូមប្រកាសបើកសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជធានី ខេត្ត ចាប់ពីពេលនេះតទៅ។

សូមអរគុណ។